# **សម្ដេច ហ៊ុន សែន : អតុល្យភាព ១០យ៉ាង**

AKP ភ្នំពេញថ្ងៃទី៥ ធ្នូ ២០០៨

<u>កំណត់ការិយាល័យនិពន្ធ:</u>

នៅពេលថ្លែងសុន្ទរកថាគន្លឹះ ក្នុងវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ នាទីក្រុងភ្នំពេញ នាថ្ងៃទី៤ ធ្នូ ឆ្នាំ២០០៨ កន្លងនេះ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក៏បានលើកឡើងបន្ថែមនូវកំណត់សំគាល់របស់លោក លើអតុល្យភាពទាំងដប់ ដែលកម្ពុជាត្រូវប្រឈមមុខហើយដែលទីភ្នាក់ងារ AKP យើងខ្ញុំសូមដកស្រង់ធ្វើការផ្សព្វផ្សាយជូនដូចខាងក្រោម :

ដើម្បីជំរាបជូនថា តើអ្វីទៅជាអតុល្យភាព១០យ៉ាងដែលត្រូវដោះស្រាយនោះគឺ **ទី១** រវាងសេចក្ដីត្រូវការ និងការផ្គត់ផ្គង់នៅប្រទេសណាក៏ដោយសេចក្ដីត្រូវការចេះតែធំ អញ្ចឹងតម្រូវការផ្គត់ផ្គង់ធំ ក៏ប៉ុន្ដែនៅកម្ពុជា សេចក្ដីត្រូវការកាន់តែធំ ក្នុងពេលដែលការផ្គត់ផ្គង់នូវមានកំរិត ដូច្នេះ គប្បីត្រូវប្រមូលផ្ដុំដោះស្រាយនូវតម្រូវការ អំពីស្បៀង និងម្ហូបអាហារ អំពីសំលៀកបំពាក់អំពីលំនៅដ្ឋាន អំពីមធ្យោបាយធ្វើដំណើរ និង ដឹកជញ្ជូន អំពីការអប់រំសិក្សាធិការ អំពីសុខាភិបាល ដែលទាក់ទងដល់ការការពារសុខភាពសំរាប់ការពិនិត្យព្យាបាលជំងឺ។ ក្នុងចំណុចនេះ បើនិយាយពីរវាងសេចក្ដីត្រូវការនៃការផ្គត់ផ្គង់គឺមានទំហំធំច្រើន ប៉ុន្ដែយើងត្រូវផ្ដល់អទិភាពប៉ុន្មាន វិស័យដែលចាំត្រូវការដោះស្រាយ ។

**<u>អតុល្យភាពទី២</u>** ដែលត្រូវទាមទារនូវការដោះស្រាយអោយបាន រវាងចំណូល និងចំណាយថវិកាជាតិ ដែលយើងត្រូវប្រមូលផ្ដុំខិតខំបង្កើនចំណូលផ្ទៃក្នុង ដើម្បីមានលទ្ធភាពយកទៅវិនិយោគជួយដល់ប្រជាជន និងត្រៀមខ្លួនអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និង កាត់បន្ថយនូវការប្រឹងប្រែងលើជំនួយ និងប្រាក់កម្ចីពីខាងក្រៅផង ប៉ុណ្ណោះហើយរវាង ចំណូល និង ចំណាយយើងនិយាយពីភាពរាំរៃ នៃឱនភាព សាច់ប្រាក់មកជាអតិរេកសាច់ប្រាក់ ក៏ប៉ុន្ដែនេះយើងនិយាយគិតអំពីថ្លឹងថ្លែងសាច់ប្រាក់តែម្ដងក៏ប៉ុន្ដែបើគិតពីកិរិយា គឺស្ថិតនៅក្នុងស្ថានភាពឱនភាពនៅឡើយទេ អញ្ចឹងការខិតខំរបស់យើងត្រូវខិតខំប្រមូលចំណាយ ប្រមូលចំណូលឱ្យបាន ឥតមានការចំណាយ ដើម្បីយកទៅប្រើប្រាស់ សំរាប់វិនិយោគឱ្យប្រជាជនតែមួយនោះទេ ម្យ៉ាងទៀតកម្មវិធីរយៈពេលវែង យើងខ្ញុំមានគោលដៅមួយផ្នែកគឺចូលរួមអនុវត្តប្រើប្រាស់អនុសាសន៍ ដល់ពេលណឹង កាត់បន្ថយពន្ធដារ ពន្ធគយ កាត់ចោលទាំងអស់ ហើយបង្កើតចំណូលទិញ ប៉ុន្ដែមួយផ្នែកទៀតយើងខ្ញុំក៏ មានគោលដៅ ដើម្បីកាត់ បន្ថយការពឹងផ្អែកពីខាងក្រៅ ទាំងជំនួយ និងការខ្ចីបុលពីបរទេសដែរ អញ្ចឹងវិធីតែម្យ៉ាង គឺដោះស្រាយចំណូលពីខាងក្នុងដោយខ្លួនឯង ។

**<u>អនុស្សាវរីយ៍ទី៣</u>** ដែលត្រូវដោះស្រាយ គឺរវាងការនាំចេញនឹងការនាំចូលដែលត្រូវដោះស្រាយឱ្យកម្ពុជាអាចពង្រីកនូវលទ្ធភាពនាំចេញសំដៅកាត់បន្ថយនូវអតុល្យភាពពាណិជ្ជកម្មក្រៅប្រទេស ដែលកំពុងមានគម្លាតយ៉ាងខ្លាំង ។

**<u>អនុស្សាវរីយ៍ទី៤</u>** ដែលត្រូវដោះស្រាយរវាងរូបិយវត្ថុនិងទំនិញដែលប្រមូលផ្តុំដោះស្រាយដោយជំរុញល្បឿន នៃកំណើនសេដ្ឋកិច្ច រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា រក្សាតម្លៃទិញនៃប្រាក់រៀល ទំនាក់ទំនងរូបិយវត្ថុ និងទំនិញឱ្យត្រឹមត្រូវនឹងស្ថានភាពយើងត្រូវរិះរកការជុំរុញល្បឿនកំណើនសេដ្ឋកិច្ច រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទប់ស្កាត់អតិផរណា និងតម្លៃទិញរបស់ប្រាក់រៀលរបស់យើង នេះវាទាក់ទងជាមួយនឹងការគ្រប់គ្រងអតិផរណា ហើយចំណុចនេះឆ្នាំ ១៩៨៧ ម្តៃមួយឆ្នាំមុន បានដាក់ចេញរួច ទៅហើយប៉ុន្តែ ក្រោយមកទៀត គឺមានតម្រូវការ ។

**<u>អនុស្សាវរីយ៍ទី៥</u>** ដែលត្រូវដោះស្រាយគឺរវាងសេចក្តីត្រូវការអំពីជីវភាពរបស់មន្ត្រីរាជការ កងកំលាំង ប្រដាប់អាវុធ ជាមួយប្រាក់បៀវត្ស។ ដើមដំបូងត្រូវស្វែងរកវិធីដើម្បីបង្កើនប្រាក់បៀវត្សឱ្យបានសមស្របតាមការរីក ចម្រើននៃសេដ្ឋកិច្ច យើងទទួលបានដោយមិនបាច់ភ័យ កំរិតនៃប្រាក់បៀវត្សរបស់មន្ត្រីរាជការ កងកំលាំងប្រដាប់ អាវុធយើងនូវទាប ឥឡូវយើងរកវិធី ដើម្បីបង្កើន យើងដាក់ចេញនូវគោលដៅ ចាប់ពីពេលនេះចាប់ពី ២០% ក្នុងមួយ ឆ្នាំ នៃការបង្កើន ក៏ប៉ុន្តែបើយើងមានលទ្ធភាពលើសពីនេះវាអាចកើនលើសពី ២០% ក៏វាមិនទាស់ខុសអីដែរ ។

**<u>អនុស្សាវរីយ៍ទី៦</u>** ដែលត្រូវដោះស្រាយគឺរវាងកំណើនពលកម្មនៃមនុស្សពេញវ័យ និសិត្សចេញពីសាលា ជាមួយនឹងការងារធ្វើ ការដោះស្រាយការងារធ្វើ ដែលត្រូវប្រមូលផ្តុំភាគីវិនិយោគ ដើម្បីបង្កើនការងារធ្វើក៏ដូចជាកែលំអ បរិស្ថានជនបទ ដើម្បីបង្កើនការងារនៅជនបទមនុស្សចេះតែកើន ក្មេងៗចេះតែពេញវ័យតម្រូវការសិស្ស និស្សិត ចេញពីសាលា ត្រូវមានបរិស្ថានអនុគ្រោះអំពីស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទាក់ទាញទុនវិនិយោគ បង្កើនការងារមួយផ្នែកទៀតមិនត្រូវភ្លេចថា ជនបទដោះស្រាយការងាររហូតដល់ ៦០% នៃប្រជាពលរដ្ឋនៃប្រទេស កសិកម្ម គ្មាននរណាធ្វើឧស្សាហកម្មទាំងអស់ទេ លើពិភពលោក កសិករគ្របដណ្តប់ ៦០% នៃការងារ អញ្ចឹងការដោះស្រាយប្រព័ន្ធទឹក ប្រព័ន្ធស្រោចស្រពផ្សេងៗ គឺជាការបង្កើនការងារ និងប្រាក់ចំណូលឱ្យប្រជាពលរដ្ឋរបស់យើង កុំនាំគ្នាទៅធ្វើបាតុកម្មដល់គេរត់ចោលអស់នោះ អញ្ចឹងទេមិនត្រឹមតែខាតការងារវានាំគ្នាគិតតែពីរឿងបាត់ការងារបន្ថែមទៀត ដូច្នេះកាន់តែអន្តរាយចង់បានច្រើនពេកត្រូវខាតៗ ។

**<u>អនុស្សាវរីយ៍ទី៧</u>** ដែលត្រូវដោះស្រាយរវាងសេចក្តីត្រូវការនៃការអភិវឌ្ឍន៍ប្រទេសជាតិ ជាមួយធនធាន មនុស្សដែលនៅទន់ខ្សោយ ដែលត្រូវប្រមូលផ្តុំដោះស្រាយវិនិយោគឱ្យវិស័យអប់រំនិង ការបណ្តុះបណ្តា

លធនធានមនុស្សប្រទេសយើង វាតម្រូវការក្នុងការអភិវឌ្ឍន៍ចាំបាច់ឱ្យមាន ការវិនិយោគទៅលើវិស័យអប់រំ និង ការបណ្តុះបណ្តាលធនធានមនុស្ស នៅតែជាអាទិភាពក្នុងការដោះស្រាយ។

**<u>អនុលោមភាពទី៨</u>** ដែលត្រូវដោះស្រាយរវាងសេចក្តីត្រូវការ អំពីការអភិវឌ្ឍន៍ ជាមួយហេដ្ឋារចនាសម្ព័ន្ធ ដែលនៅទន់ខ្សោយ ដែលត្រូវប្រមូលផ្តុំការខិតខំការវិនិយោគ ដែលផ្តល់អាទិភាពសំខាន់ទៅលើវិស័យប្រព័ន្ធទឹកស្រោចស្រព ផ្លូវ ស្ពាន ផ្លូវដែក កំពង់ផែ អាកាសយានដ្ឋាន និងអគ្គីសនី ។ល។

**<u>អនុលោមភាពទី៩</u>** រវាងសេចក្តីត្រូវការនៃការអភិវឌ្ឍន៍ប្រកបដោយតម្លាភាព និងចរិភាព ជាមួយ និងអភិបាលកិច្ចខ្វះប្រសិទ្ធភាព ដែលត្រូវប្រមូលផ្តុំដោះស្រាយទៅលើការពង្រឹងអភិបាលកិច្ចល្អ ប្រឆាំងនឹងអំពើពុករលួយ បង្កើនប្រសិទ្ធភាព និងចិរភាព ចំណុចនេះយុទ្ធសាស្ត្រចតុកោណបានដាក់ចេញនៅចំណុចកណ្តាលនៃការ អភិបាលកិច្ច ការអភិវឌ្ឍន៍ដោយតម្លាភាព និងចិរភាពវាជាការចាំបាច់ ។

**<u>អនុលោមភាពទី១០</u>** ដែលត្រូវដោះស្រាយរវាង ម្ខាងសេចក្តីត្រូវការ ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចជាតិ ទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក និងម្ខាងទៀត ភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ និងសម្ថភាព ស្ថាប័ន ក្របខ័ណ្ឌគតិយុត្តិ និងសមត្ថភាព និង ការកសាងសមត្ថភាពស្ថាប័ន ។